ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៥ សរណន

**សារាចរណែនាំ**
**ស្តីពី**
**ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២**

**១-សេចក្តីផ្តើម**

មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបានចែងថា ប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ចែកជា ៣ ដំណាក់កាល÷ **ដំណាក់កាលទី ១** គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែ មីនា ដល់ខែ ឧសភា, **ដំណាក់កាលទី ២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែ មិថុនា ដល់ខែ កញ្ញា និង**ដំណាក់កាលទី ៣** គឺការអនុម័តថវិកា ចាប់ពីខែ តុលា ដល់ខែ ធ្នូ។ សម្រាប់ដំណាក់កាលទី ១ នេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០២០ ដើម្បីឱ្យក្រសួង-ស្ថាប័នសាមីនីមួយៗ មានមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២ និងការលើកគម្រោងថវិកាប្រចាំឆ្នាំ ២០២០។ នៅជំហានបន្ទាប់ រាជរដ្ឋាភិបាលត្រូវដាក់ចេញនូវសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗ និងមគ្គុទ្ទេសបច្ចេកទេសគន្លឹះៗ សម្រាប់គ្រប់ក្រសួង-ស្ថាប័នធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិកា ដែលជាផែនការថវិការយៈពេល ០៣ ឆ្នាំរំកិល ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំនៅដំណាក់កាលទី ១ នៃដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ។ ដោយឡែកចំពោះការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងមានសារាចរណែនាំដោយឡែកមួយផ្សេងទៀត ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។

ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍មួយដ៏សំខាន់សម្រាប់÷(១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

របស់ក្រសួង-ស្ថាប័ន និងគោលនយោបាយរបស់រាជរដ្ឋាភិបាល, (២)-បង្កើនវិចារណកម្មអាទិភាពចំណាយឱ្យកាន់តែឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន, (៣)-ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង-ស្ថាប័ន ដើម្បីសម្រេចគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ (៤)-ជាមូលដ្ឋានសម្រាប់ពន្យល់ និងបង្ហាញសេចក្តីសំអាងអំពីតម្រូវការថវិកាសម្រាប់អនុវត្តគោលនយោបាយ និង (៥)-ជាមូលដ្ឋានសម្រាប់ការរៀបចំ និងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។ ដូច្នេះ ផែនការយុទ្ធសាស្ត្រថវិកាត្រូវតែឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័នសាមីនីមួយៗ, អំពីកម្មវិធីច្បាស់លាស់, អំពីសូចនាករ និងគោលដៅសូចនាករសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្តកម្មវិធី សមស្របនឹងទំហំថវិកា និងលទ្ធភាពថវិកាដែលមាន ដើម្បីរួមចំណែកសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ក្រសួង-ស្ថាប័នមួយត្រូវមានផែនការយុទ្ធសាស្ត្រថវិការួមមួយដែលគ្របដណ្តប់ទាំងថវិការដ្ឋបាលកណ្តាល, ថវិកាមន្ទីរជំនាញរាជធានី-ខេត្ត និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមឱវាទក្រសួង-ស្ថាប័ននោះ។

ទន្ទឹមនេះ ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍សំខាន់សម្រាប់ធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ព្រមទាំងរវាងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានគុណភាពកាន់តែល្អប្រសើរ ក៏ដូចជាជួយលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជ និងគ្រប់គ្រងថវិកាប្រចាំឆ្នាំផងដែរ។ ដូចនេះ *ក្រសួង-ស្ថាប័ននីមួយៗ ត្រូវជំរុញ និងលើកទឹកចិត្តដល់**ក្រុមការងារថវិកា**របស់ខ្លួនដែលមានសមាសភាពមកពីនាយកដ្ឋានថវិកា/ហិរញ្ញវត្ថុ ឬ/និងគណនេយ្យដែលហៅថា "អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ", នាយកដ្ឋានផែនការ, អង្គភាពថវិកា/អង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងគម្រោងឱ្យដំណើរការដោយសកម្ម និងប្រកបដោយការទទួលខុសត្រូវខ្ពស់*។ ដូចនេះ **ក្រុមការងារថវិកា** ត្រូវខិតខំធានាឱ្យប្រាកដថា ទាំងធនធាន និងទាំងសកម្មភាពការងារទាំងអស់របស់ក្រសួង-ស្ថាប័នខ្លួន ត្រូវបានដាក់បញ្ចូល ឬឆ្លុះបញ្ចាំងក្នុងផែនការយុទ្ធសាស្ត្រថវិកា សំដៅធានាថាថវិកាត្រូវបានវិភាជត្រង់ទៅចំសកម្មភាព និងចំសេចក្តីត្រូវការយ៉ាងពិតប្រាកដរបស់អង្គភាពអនុវត្តសកម្មភាពរៀងខ្លួន ព្រមទាំងធានាបាននូវតុល្យភាពនៃការវិភាជថវិកា ហើយឆ្លើយតបបានជាអតិបរមាទៅនឹងគោលបំណងគោលនយោបាយ និងរវាងកម្មវិធីដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។

លើសពីនេះ ដើម្បីធានាគុណភាព ប្រសិទ្ធភាព និង ជោគជ័យពិតប្រាកដនៃ **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** ដែលជាគោលដៅសំខាន់នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ-ដំណាក់កាលទី ៣ (២០១៦-២០២០), ក្រសួង-ស្ថាប័ននីមួយៗត្រូវយកចិត្តទុកដាក់កែលម្អគុណភាពផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២ ដោយធានាការផ្សារភ្ជាប់ទៅនឹងអាទិភាពគោលនយោបាយដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលអាណត្តិទី ៦ នៃរដ្ឋសភាជាតិ ស្របតាមគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការណែនាំបន្ថែមតាមរយៈសារាចរណែនាំប្រចាំឆ្នាំនេះ។

*ដូចនេះ គ្រប់ក្រសួង-ស្ថាប័ន ចាំបាច់ត្រូវរៀបចំឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងលើកិច្ចការនេះបន្ថែមទៀត ដោយកំណត់ឱ្យបានច្បាស់អំពីតួនាទីរបស់អគ្គនាយកដ្ឋាន/នាយកដ្ឋានពាក់ព័ន្ធ និងតួនាទីរបស់*

*អគ្គនាយកដ្ឋាន/នាយកដ្ឋាន ថវិកា/ហិរញ្ញវត្ថុ ដែលជា "អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ" ព្រមទាំងអាចដាក់ចេញជាគោលការណ៍ណែនាំផ្ទៃក្នុងស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក៏ដូចជាគោលការណ៍ណែនាំផ្ទៃក្នុងសម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំផងដែរ ជាពិសេសសម្រាប់ក្រសួង-ស្ថាប័នដែលមិនទាន់បានបង្កើតនូវយន្តការនេះ ឬក៏បានបង្កើតរួចហើយ តែដំណើរការមិនទាន់បានរលូន ឬគ្មានប្រសិទ្ធភាព។ ដូចឆ្នាំកន្លងមកផងដែរ ក្រសួង-ស្ថាប័ននីមួយៗ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តល់កិច្ចសហការល្អរវាងគ្នាទៅវិញទៅមក ដោយអនុញ្ញាតឱ្យ**ក្រុមការងារថវិកា**តាមក្រសួង-ស្ថាប័នសាមី មានភាពជាម្ចាស់ក្នុងការធ្វើការងារជាមួយមន្ត្រីជំនាញថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ដើម្បីពិនិត្យឡើងវិញ និងកែលម្អរចនាសម្ព័ន្ធកម្មវិធី និងសូចនាករសមិទ្ធកម្ម តាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធីនីមួយៗ** ក្នុងគោលបំណងដើម្បីបង្កើនគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក៏ដូចជាប្រសិទ្ធភាពក្នុងការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ។*

ក្នុងគោលដៅបង្កើនគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា, ស្របតាមទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, **ក្របខ័ណ្ឌថវិការយៈពេលមធ្យម (ក.ថ.ម)** ត្រូវបានដាក់អនុវត្តសាកល្បងចាប់ពីឆ្នាំ ២០២០ ដើម្បីផ្តល់ជាកញ្ចប់ថវិកាក្នុងកម្រិតពិតានចំណាយគោលមួយជូនដល់ក្រសួង-ស្ថាប័ន ដូចមានលម្អិតនៅក្នុងផ្នែក **២.៣** សម្រាប់រៀបចំផែនការថវិការយៈពេលមធ្យម ៣ ឆ្នាំ រំកិល ទៅតាមរចនាសម្ព័ន្ធ កម្មវិធី និងគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ ហើយដែលនឹងរួមចំណែកសម្រេចអាទិភាពគោលនយោបាយតាមវិស័យ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ក្នុងន័យនេះ ដើម្បីជួយដល់ក្រសួង-ស្ថាប័ន មានមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២ ឱ្យកាន់តែមានភាពជាក់ស្តែង រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង-ស្ថាប័ន ដូចខាងក្រោម÷

## ២-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ បានផ្តល់ទស្សនៈវិស័យទូលំទូលាយនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណត់អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងនិន្នាការចំណូល និងចំណាយថវិកាជាតិសម្រាប់រយៈពេលមធ្យម ២០២០-២០២២ ក៏ដូចជាផ្តល់នូវលំហថវិការួមសម្រាប់គ្រប់ក្រសួង-ស្ថាប័នធ្វើការកំណត់អាទិភាពសកម្មភាពការងារសម្រាប់រយៈពេលខ្លី និងមធ្យមរបស់ខ្លួន។ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏កំណត់ផងដែរអំពីលទ្ធភាពផ្នែកធនធាន និងអាទិភាពគោលនយោបាយចម្បងៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូចនេះអាចនិយាយបានថា នៅក្នុងដំណើរការនៃការរៀបចំផែនការថវិកា ការកំណត់ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការពីលើចុះក្រោម ចំណែកឯ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការពី

ក្រោមឡើងលើ។ យន្តការទាំងពីរនេះ គឺមានភាពចាំបាច់មិនអាចខ្វះបានដើម្បីធានាប្រសិទ្ធភាព និងភាពប្រាកដប្រជាអំពីលទ្ធភាពថវិកា និងការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសូមគូសរំលេចនូវខ្លឹមសារស្នូលនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានរៀបចំដូចខាងក្រោម÷

**២.១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច**

ផ្អែកលើចលនការកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជានៅក្នុងរយៈពេល ៥ ឆ្នាំ កន្លងមកនេះ, កំណើនសេដ្ឋកិច្ចឆ្នាំ ២០១៩ ត្រូវបានព្យាករថា អាចសម្រេចបានក្នុងរង្វង់ ៧,១% ដូចការគ្រោងទុកក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩។ ដោយឡែកសម្រាប់ឆ្នាំ ២០២០, សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងថមថយកំណើនមកត្រឹម ៦,៥% ដោយសារការរំពឹងទុកផលប៉ះពាល់នៃលទ្ធភាពក្នុងការដក EBA ដែលអាចនឹងដាក់សម្ពាធដល់ការនាំចេញរបស់កម្ពុជា ជាពិសេសលើផលិតផលកាត់ដេរទៅកាន់ទីផ្សារអឺរ៉ុប។ កំណើននេះត្រូវបានគាំទ្រដោយកំណើននៃវិស័យកសិកម្មប្រមាណ ១,៧% និងកំណើនវិស័យឧស្សាហកម្មប្រមាណ ៨,៩%, ដែលវិស័យនេះគាំទ្រដោយកំណើនខ្ពស់នៃវិស័យសំណង់ និងវិស័យឧស្សាហកម្មផ្សេងទៀត ខណៈដែលវិស័យកាត់ដេរត្រូវបានព្យាករថានឹងមានកំណើនទាបប្រមាណ ៣,៥% និងវិស័យសំណង់អាចសម្រេចបានប្រមាណ ១៦,១%, ព្រមទាំងកំណើនវិស័យសេវាកម្មអាចនឹងសម្រេចបានក្នុងរង្វង់ ៦,៤%។

អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ ត្រូវបានព្យាករថានឹងស្ថិតក្នុងកម្រិតទាប ប្រមាណជា ២,៨% និង ២,៩% ក្នុងឆ្នាំ ២០១៩ និងឆ្នាំ ២០២០ ដោយសារការរំពឹងទុកនៃកំណើនយឺតនៃថ្លៃម្ហូបអាហារ និងថ្លៃដឹកជញ្ជូន។ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ត្រូវបានរំពឹងថានឹងមានស្ថិរភាពក្នុងឆ្នាំ ២០១៩ និងឆ្នាំ ២០២០ ពោលគឺស្ថិតក្នុងរង្វង់ ៤ ០៥០ រៀលក្នុងមួយដុល្លារអាមេរិក ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ជំនឿទុកចិត្តពីសំណាក់សាធារណជនលើការប្រើប្រាស់ប្រាក់រៀល តាមរយៈការអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុ។

ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងស្ថិតក្នុងអត្រា ៩,៦% និង ៩,៣% នៃ ផសស ក្នុងឆ្នាំ ២០១៩ និងឆ្នាំ ២០២០។ ការរួមតូចនៃឱនភាពគណនីចរន្តនេះ នឹងត្រូវឆ្លុះបញ្ចាំងតាមរយៈការរំពឹងទុកការបន្តកើនឡើងនៃចំណូលដែលបានពីភ្ញៀវទេសចរអន្តរជាតិ និងការថយចុះនៃឱនភាពសមតុល្យពាណិជ្ជកម្ម ដោយសារការថមថយនៃការនាំចូលវត្ថុធាតុដើមកាត់ដេរ ស្របនឹងកំណើនទាបនៃការនាំចេញផលិតផលកាត់ដេរ ។ ទុនបម្រុងអន្តរជាតិសរុបត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ប្រមាណ ១១ ៥០៥ លានដុល្លារអាមេរិក និង ១៣ ០០៧ លានដុល្លារអាមេរិក ដែលធានាការនាំចូលឆ្នាំបន្ទាប់បាន ៥,៨ ខែ និង ៦,១ ខែ។

**២.២-ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ**

ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២០ ដែលត្រូវបានរៀបចំ ដោយឈរលើមូលដ្ឋាននៃ

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដូចបានគូសបញ្ជាក់ខាងលើ និង **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤"** មានគោលបំណងដូចតទៅ÷

- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ;
- បន្តធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន, ការងារ, សមធម៌ និងប្រសិទ្ធភាព ក្នុងគោលដៅបែងចែកផ្លែផ្កានៃកំណើន ប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន;
- បន្តធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ ដើម្បីសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចរឹងមាំ ប្រកបដោយបរិយាប័ន្ន និងចីរភាព ក្នុងបរិការណ៍នៃភាពមិនច្បាស់លាស់ និងហានិភ័យ ព្រមទាំងធានាបាននូវអត្រាអតិផរណាដែលអាចគ្រប់គ្រងបាន និងស្ថិរភាពអត្រាប្តូរប្រាក់;
- បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ;
- ជំរុញប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥ ដែលរួមមានការដាក់ឱ្យអនុវត្តសាកល្បងនូវក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ២០២០-២០២២ និងក្របខ័ណ្ឌថវិការយៈពេលមធ្យម ២០២០-២០២២ ;
- ដាក់ឱ្យអនុវត្តក្របខ័ណ្ឌចំណាយអន្តរាគមន៍ ប្រកបដោយប្រសិទ្ធភាពទាំងក្នុងកម្រិតវិភាជ និងប្រតិបត្តិការក្នុងបរិការណ៍នៃការកើនឡើងនូវភាពមិនច្បាស់លាស់ និងហានិភ័យមកលើសេដ្ឋកិច្ចកម្ពុជា;
- បន្តគិតគូរលើការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលក្នុងកម្រិតសមស្រប ដោយផ្អែកទៅលើសមិទ្ធកម្ម ឬគុណាធិបតេយ្យ ដើម្បីបន្តពង្រឹងសមត្ថភាពស្ថាប័ន និងអភិបាលកិច្ច ក្នុងគោលដៅធានាប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, គណនេយ្យភាព និងតម្លាភាពនៃការផ្តល់សេវាសាធារណៈ;
- បន្តអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាពសំដៅធានាបាននូវចីរភាពបំណុល;
- ពន្លឿនការអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការ នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ តាមរយៈការគាំទ្រការអភិវឌ្ឍវិស័យឯកជន និងការបង្កើនវិនិយោគសាធារណៈលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តលើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន និងវិស័យថាមពល ក៏ដូចជាការតភ្ជាប់វិស័យឌីជីថល ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី ៤;
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម និងខ្ពស់ ព្រមទាំងសុខុមាលភាពសង្គមដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ ឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការទីផ្សារ

- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ដោយផ្ដោតលើការបង្កើនផលិតភាព, ពិពិធកម្ម, ការកែច្នៃកសិផល និងពាណិជ្ជូបនីយកម្ម។

ដើម្បីសម្រេចបានតាមគោលដៅនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌគោល-នយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ រាជរដ្ឋាភិបាលបានកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ ២០២០ ដូចខាងក្រោម÷

- ក្នុងបរិការណ៍កំណើនចំណូលនឹងមានល្បឿនយឺតជាងមុន ស្របនឹងការថមថយកំណើនសេដ្ឋកិច្ចជារួម **ចំណូលក្នុងស្រុក**សរុបសម្រាប់ឆ្នាំ ២០២០ ត្រូវគ្រោងសម្រេចឱ្យបាន ២២,៥២% នៃ ផសស ក្នុងនោះចំណូលចរន្តក្នុងទំហំ ២២,៣៦% នៃ ផសស និងចំណូលមូលធនក្នុងទំហំ ០,១៦% នៃ ផសស។ ចំណូលចរន្តនឹងមានកំណើន ២៦,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៩ ដែលក្នុងនោះ ថ្នាក់ជាតិត្រូវសម្រេចឱ្យបានប្រមាណ ២០,៤៤% នៃ ផសស និងសម្រាប់ថ្នាក់ក្រោមជាតិ ១,៩២% នៃ ផសស។ ដោយឡែក ការប្រមូលចំណូលពីអគ្គនាយកដ្ឋានពន្ធដារ ត្រូវគ្រោងសម្រេចឱ្យបាន ៩,៦៩% នៃ ផសស, ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវគ្រោងសម្រេចឱ្យបាន ៩,៧៨% នៃ ផសស និងចំណូលមិនមែនសារពើពន្ធត្រូវគ្រោងសម្រេចឱ្យបាន ២,៨៨% នៃ ផសស ។
- ក្នុងការត្រៀមខ្លួនឱ្យបានរួចរាល់ឆ្លើយតបទៅនឹងហានិភ័យដែលអាចកើតឡើងជាយថាហេតុ និងអនុវត្តអន្តរាគមន៍ចាំបាច់នានា **ចំណាយសរុបថវិការដ្ឋ**នៅឆ្នាំ ២០២០ នឹងកំណត់ក្នុងរង្វង់ ២៨,៤០% នៃ ផសស ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិ ២៦,៤៨% នៃ ផសស និងចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ ២,៨៣% នៃ ផសស ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធន ដល់ថ្នាក់ក្រោមជាតិចំនួន ០,៩១% នៃ ផសស ។ ចំណាយចរន្តថវិការដ្ឋត្រូវកំណត់ក្នុងកម្រិត ១៦,៧៥% នៃ ផសស ដែលក្នុងនោះ÷
    - **ចំណាយបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៤៦,៣% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៧,៧៥% នៃ ផសស ដែលត្រូវបានផ្ដោតអាទិភាពលើការបង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដើម្បីបង្កើនផលិតភាពការងារ និងពង្រឹងការផ្ដល់សេវាសាធារណៈ។
    - **ចំណាយក្រៅបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៥៣,៧% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៩,០% នៃ ផសស ដោយផ្ដោតសំខាន់លើតម្រូវការចំណាយសម្រាប់ទ្រទ្រង់ដល់ការកែទម្រង់នានា និងការអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជា ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមជាដើម ។

ទន្ទឹមនេះ សម្រាប់ឆ្នាំ ២០២០ ចំណាយមូលធនត្រូវបានគ្រោងបង្កើនដល់ប្រមាណជា ១១,៦៥% នៃ ផសស ក្នុងគោលដៅជួយទ្រទ្រង់ផលិតភាពក្នុងសេដ្ឋកិច្ច, អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងជំរុញកំណើនសេដ្ឋកិច្ច។

**សរុបចំណាយថវិកាថ្នាក់ជាតិ** ដែលរួមបញ្ចូលទាំងហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងវិភាជទៅតាមវិស័យដូចខាងក្រោម÷

- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ២,២៥% នៃ ផសស និងមានការកើនឡើង ៨,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៩;
- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ៣,៩៩% នៃ ផសស និងមានកំណើន ៧,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៩;
- **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៧,៦១% នៃ ផសស និងមានកំណើន ២៥,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៩ និង
- **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ៧,៥៨% នៃ ផសស និងមានកំណើន ៣៦,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៩ ។

ដូចនេះ ដោយឈរលើមូលដ្ឋានក្របខ័ណ្ឌចំណូល និងចំណាយខាងលើ, អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ ២០២០ នឹងសម្រេចបានប្រមាណ ៥,៦១% នៃ ផសស និងឱនភាពថវិកាសរុបនឹងត្រូវឡើងដល់ ៥,៨៨% នៃ ផសស ។ ក្នុងក្របខ័ណ្ឌនេះ ថវិកាឆ្នាំ ២០២០ មានចរិតជាការពង្រឹងវិន័យ និងប្រសិទ្ធភាពថវិកា តាមរយៈការរក្សាសមតុល្យថវិកា និងការផ្តោតកាន់តែសំខាន់លើប្រសិទ្ធភាពចំណាយ ទាំងកម្រិតវិភាជ និងប្រតិបត្តិការ។

ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ, ការគ្រោងថវិកាឆ្នាំ ២០២០ និងឆ្នាំបន្តបន្ទាប់ ត្រូវរៀបចំឡើងឈរលើមូលដ្ឋានយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃវិធានការ ដូចខាងក្រោម÷

### ក. វិធានការផ្នែកចំណូល

### ក.១-វិធានការផ្នែកចំណូលពន្ធដារ

វិធានការគន្លឹះជាក់លាក់សម្រាប់ការអនុវត្តនៅក្នុងឆ្នាំ ២០២០ ក្នុងទិសដៅរក្សាកំណើនចំណូលពន្ធ និងឆ្លើយតបនឹងបញ្ហាប្រឈម រួមមាន÷

- ***បន្តពង្រឹងមុខងារប្រតិបត្តិការស្នូល រួមមាន ការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា÷***
  - រៀបចំកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យចុះបញ្ជីពន្ធដារដើម្បីសម្រួលដល់អ្នកជាប់ពន្ធក្នុងការចុះបញ្ជី និងរៀបចំយន្តការចុះបញ្ជីពន្ធដារតាមប្រព័ន្ធស្វ័យប្រវត្តិកម្មជាមួយក្រសួង-ស្ថាប័ន ផ្សេងៗ;
  - បន្តពង្រឹងការចុះបញ្ជីពន្ធដារចំពោះសហគ្រាសដែលមិនទាន់បានចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ដែលបានពីលទ្ធផលនៃការចុះអង្កេតសហគ្រាស និងផ្ទៀងផ្ទាត់ព័ត៌មានរបស់អ្នកជាប់ពន្ធជាមួយស្ថាប័នផ្សេងៗ;

- បញ្ជ្រាបវប្បធម៌នៃការបង់ពន្ធ តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាល, សិក្ខាសាលា និងវេទិកាពិគ្រោះយោបល់ជាមួយវិស័យឯកជន អំពីការផ្តល់សេវាពន្ធដារ;
- រៀបចំ និងអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់អនុលោមភាពស្ម័គ្រចិត្ត ដែលមានលក្ខណៈនវានុវត្តន៍ និងគ្រប់ជ្រុងជ្រោយ ជាពិសេសការពង្រឹងគុណភាពសេវា និងការអប់រំអ្នកបង់ពន្ធ;
- ជំរុញការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចក្នុងការចុះបញ្ជី (e-registration), ការដាក់លិខិតប្រកាសពន្ធ (e-filing), និងការបង់ប្រាក់ពន្ធ (e-payment) ឱ្យមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡាតាមនិយាមអន្តរជាតិ;
- ធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តផែនការ និងនីតិវិធីសវនកម្មរួម ដើម្បីដោះស្រាយបញ្ហាការធ្វើសវនកម្មច្រើនដង, អសង្គតិភាពនៃការអនុវត្តនីតិវិធីសវនកម្ម និងការកាត់បន្ថយនូវបន្ទុកការងាររបស់សវនករ;
- ដាក់ឱ្យអនុវត្តផែនការជាតិស្តីពីសវនកម្ម (national audit plan) ដើម្បីកំណត់អត្តសញ្ញាណជាយុទ្ធសាស្ត្រក្នុងការវិភាគហានិភ័យ និងពង្រឹងការធ្វើសវនកម្មដោយផ្អែកលើកម្រិតហានិភ័យ (risk-based audit);
- បន្តជ្រើសរើសសហគ្រាសដែលមានបុត្រសម្ព័ន្ធ ជាអាទិភាពក្នុងការធ្វើសវនកម្មលើការផ្ទេរថ្លៃរវាងសហគ្រាស;
- ជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និងបន្ថយបន្ទុកសវនកម្ម;
- ដាក់ឱ្យអនុវត្តតារាងតម្លៃថ្មីសម្រាប់ជាមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ, ពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និង
- ពង្រឹងយន្តការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ ដើម្បីធានាទំនុកចិត្តរបស់អ្នកបង់ពន្ធ ។

- ***បន្តពង្រឹងមុខងារគាំទ្រ ៖***
  - បន្តរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីបង្កើនការប្រមូលចំណូលពន្ធ;
  - បន្តសិក្សាស្រាវជ្រាវ ប្រមូលផ្តុំ និងកែសម្រួលចំណុចខ្វះខាតនៃច្បាប់ស្តីពីសារពើពន្ធ;
  - ពង្រឹងយន្តការតាមដាន, វិភាគ, វាយតម្លៃ និងផ្តល់យោបល់លើការអនុវត្តគោលនយោបាយពន្ធដារកម្ពុជា និងការកែប្រែគោលនយោបាយពន្ធដារនៃប្រទេសក្នុងតំបន់ និងសកលលោក;
  - ដាក់ឱ្យអនុវត្តការរៀបចំឡើងវិញនូវដំណើរការការងារ និងផែនការគ្រប់គ្រងការផ្លាស់ប្តូរស្ថាប័ន (organizational change management) ដើម្បីធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា;

- បន្តពង្រឹងសមត្ថភាព និងភាពជាអ្នកដឹកនាំរបស់អ្នកគ្រប់គ្រង និងមន្ត្រីជំនាញ តាមរយៈការបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស;
- ដាក់ឱ្យអនុវត្តគោលការណ៍ស្តីពីការគ្រប់គ្រងចាត់ចែងចំនួនមន្ត្រី និងបង្កើតនីតិវិធីប្រតិបត្តិសម្រាប់ការគ្រប់គ្រង (standard operating procedure) នៅគ្រប់អង្គភាពពន្ធដារ;
- ផ្តល់សិទ្ធិអំណាច និងពង្រឹងប្រសិទ្ធភាពសវនកម្មផ្ទៃក្នុង ដើម្បីធានាតម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចផ្ទៃក្នុង;
- បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា និងបន្ថែមមុខងារថ្មីៗ ក្នុងប្រព័ន្ធនៃការគ្រប់គ្រងការចុះបញ្ជីសហគ្រាស, ការធ្វើសវនកម្ម, ការបង្វិលសង VAT, ការចុះបញ្ជីអចលនទ្រព្យ, ការបង់ប្រាក់ពន្ធ, ការតាមដាន និងវិភាគចំណូល, ការតាមដានឯកសារចេញ-ចូល និងការគ្រប់គ្រងធនធានមនុស្ស;
- រៀបចំបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ ១). Help desk system ដើម្បីផ្តល់ការគាំទ្របច្ចេកទេសដល់អ្នកប្រើប្រាស់ឱ្យមានប្រសិទ្ធភាព, ២). ការអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA system), ៣). ការគ្រប់គ្រងដំណើរការនៃការស៊ើបអង្កេតបទល្មើសពន្ធដារ និង ៤). ការបញ្ចូលទិន្នន័យលិខិតប្រកាសប្រចាំខែ និងប្រចាំឆ្នាំ ដោយស្វ័យប្រវត្តិ (automated data capturing system) សម្រាប់អ្នកជាប់ពន្ធតូច មធ្យម និងធំ និង
- សិក្សា និងបង្កើតមជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខបច្ចេកវិទ្យាព័ត៌មាន (security operation center - SOC) ។

**ក.២-វិធានការផ្នែកចំណូលគយ និងរដ្ឋាករ**

ក្នុងទិសដៅបន្តពង្រឹងប្រភពចំណូលសំខាន់ ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលនឹងអាចកើតមានក្នុងឆ្នាំ ២០២០ វិធានការគន្លឹះ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តឆ្នាំ ២០២០ ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា មាន ២ផ្នែក និងផ្តោតលើគោលដៅជាអាទិភាព ដែលត្រូវអនុវត្តក្នុងឆ្នាំ ២០២០ រួមមាន៖

- ***បន្តពង្រឹងរដ្ឋបាលគយ និងកិច្ចសម្រួលពាណិជ្ជកម្ម៖***
  - កាត់បន្ថយ និងធ្វើសាមញ្ញកម្មនីតិវិធីគយ ឱ្យកាន់តែខ្លី និងងាយស្រួល តាមរយៈការធ្វើវិមជ្ឈការ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងកិច្ចសហប្រតិបត្តិការគយ;
  - បន្តអនុវត្តយន្តការលើកទឹកចិត្តដល់ធុរជនដែលមានអនុលោមភាពខ្ពស់តាមរយៈការផ្តល់ប្រព្រឹត្ត-កម្មពិសេសក្នុងការបំពេញបែបបទគយ និងត្រូវពិនិត្យលទ្ធភាពបង្កើនចំនួន Best traders ហើយត្រូវចាប់ផ្តើមរៀបចំអនុវត្តយន្តការ AEO (Authorized Economic Operator) ជាមួយប្រទេសជិតខាង ឬជាមួយប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា;

- កែលម្អប្រព័ន្ធស្វ័យប្រវត្តិកម្មគយ, ប្រព័ន្ធ e-customs, ប្រព័ន្ធគ្រប់គ្រងហានិភ័យ និងយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ;
- ជំរុញអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិពេញលេញឱ្យបានឆាប់រហ័ស;
- កែលម្អវិធីសាស្ត្រនៃការកំណត់សូចនាករហានិភ័យដើម្បីបង្កើនប្រសិទ្ធភាពប្រព័ន្ធទិន្នន័យសម្រាប់គ្រប់គ្រងហានិភ័យគយ (customs risk management database system);
- ពិនិត្យ និងវាយតម្លៃឡើងវិញលើ ១). បញ្ជីទំនិញហាមឃាត់ និងជាប់កម្រិតកំណត់ (prohibited and restricted goods) និង ២). ភាពចាំបាច់នៃការប្រើប្រាស់លិខិតអនុញ្ញាតគយសម្រាប់ការនាំចេញ និងការនាំចូល ដើម្បីជួយសម្រួលបន្ទុករដ្ឋបាល ក៏ដូចជារួមចំណែកក្នុងការកាត់បន្ថយបន្ទុកចំណាយ និង
- បន្តពង្រឹងប្រសិទ្ធភាពការងារបច្ចេកទេសគយ, ការអនុវត្តនីតិវិធីគយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ។

- ***បន្តពង្រឹងគោលនយោបាយពន្ធគយ និងអភិបាលកិច្ច៖***
    - បន្តធ្វើការវាយតម្លៃផលប៉ះពាល់លើចំណូលពន្ធគយដែលបាត់បង់ពីការអនុវត្ត FTAs, ការកើនឡើងនូវផលិតផលក្នុងស្រុកជំនួសការនាំចូល និងការកើនឡើងនៃការប្រើប្រាស់ថាមពលពីប្រភពមិនមែនប្រេងឥន្ធនៈ;
    - ពិនិត្យលទ្ធភាពកែសម្រួលមូលដ្ឋានគិតពន្ធ និងអត្រាអាករពិសេសលើទំនិញដែលមានលក្ខណៈប្រណិត, ប៉ះពាល់បរិស្ថាន និងសុខភាព ដើម្បីប៉ះប៉ូវការបាត់បង់ចំណូលក្នុងករណីចាំបាច់;
    - ចូលរួមអនុវត្តគោលនយោបាយលើកទឹកចិត្តវិស័យអាទិភាព ដូចជា វិស័យកសិកម្ម, កម្មន្តសាល និងសហគ្រាសធុនតូច និងមធ្យម តាមរយៈ ១). ការពិនិត្យរកមុខទំនិញដើម្បីបញ្ចុះអត្រាពន្ធអាករនាំចូល, និង ២). លើកសំណើទៅក្រុមការងារតារាងពន្ធគយអាស៊ាន (AHTN task force) ក្នុងការញែកលេខកូដចំពោះបន្ទាត់ពន្ធណាដែលមានមុខទំនិញបម្រើច្រើនវិស័យដើម្បីជាមូលដ្ឋានអាចកំណត់អត្រាពន្ធគយខុសគ្នាឱ្យស្របតាមវិស័យនីមួយៗ;
    - អនុវត្តសវនកម្មគយពេញលេញ (comprehensive custom audit) តាមរយៈការចុះត្រួតពិនិត្យផ្ទាល់ដល់ទីកន្លែង ជាជាងការត្រួតពិនិត្យតែលើឯកសារ;
    - កំណត់ក្រុមហ៊ុនដែលត្រូវធ្វើសវនកម្មដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ដើម្បីបង្កើនប្រសិទ្ធភាពសវនកម្ម;
    - បញ្ចប់ និងអនុវត្តយុទ្ធសាស្ត្រជំរុញការអនុវត្តច្បាប់ (enforcement strategy) និងយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន (ICT strategy);
    - ពិនិត្យឡើងវិញ កម្រិតពិន័យបទល្មើសគយ ដើម្បីធានាប្រសិទ្ធភាពការងារបង្ការបទល្មើស;

- កែលម្អ និងពង្រឹងយន្តការគ្រប់គ្រងព័ត៌មានបទល្មើសគយ ដោយបែងចែកឱ្យបានច្បាស់លាស់រវាងចំណូល និងប្រាក់ពិន័យដែលបានពីករណីបទល្មើសតូច និងធំ;
- តាមដាន និងវាយតម្លៃប្រសិទ្ធភាពការងារបង្ការ និងបង្ក្រាបបទល្មើសគយ ជាពិសេសការងាររបស់ការិយាល័យនាវាចរគយ;
- ពង្រឹងការចែករំលែកព័ត៌មាន និងទិន្នន័យ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាប្រសិទ្ធភាពការងារ និង
- ជំរុញលើកកម្ពស់អនុលោមភាពវិស័យឯកជន ដោយពង្រឹងក្រមសីលធម៌ជើងសារគយ, បង្កើនការផ្សព្វផ្សាយ និងការយល់ដឹងដល់ធុរជនអំពីតម្លៃ និងកិត្តិយសនៃវប្បធម៌បង់ពន្ធស្អាតស្អំ និងផលវិបាកនៃអំពើគេចវេស និងបន្លំពន្ធ។

**ក.៣- វិធានការផ្លែកចំណូលមិនមែនសារពើពន្ធ**

ក្នុងទិសដៅបន្តកំណើន និង ពង្រឹងប្រភពចំណូលសក្តានុពលបន្ថែមលើវឌ្ឍនភាពសម្រេចកន្លងមក ក៏ដូចជាឆ្លើយតបនឹងបញ្ហាប្រឈមផ្សេងៗដែលអាចនឹងកើតមានឡើងក្នុងឆ្នាំ ២០២០ វិធានការគន្លឹះប្រចាំគ្រាដែលចាំបាច់ត្រូវបន្តអនុវត្ត រួមមាន÷

- បង្កើនប្រសិទ្ធភាពនៃដំណើរការរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធដើម្បីធ្វើការតាមដាន និងរៀបចំរបាយការណ៍បូកសរុបជូនប្រមុខរាជរដ្ឋាភិបាលស្តីពីស្ថានភាពនៃការប្រមូលចំណូលរបស់ក្រសួង-ស្ថាប័ននៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ;
- បង្កើនកិច្ចសហការរវាងថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័ន ដែលទទួលខុសត្រូវតាមដាន និងផ្តល់ព័ត៌មាន, កត់ត្រា, កៀរគរចំណូល និងចាត់វិធានការតឹងទារបំណុលឱ្យបានទាន់ពេលជាមួយយន្តការ ដែលមានស្រាប់;
- បន្តពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលមិនមែនសារពើពន្ធ តាមរយៈការពង្រឹងយន្តការស្ថាប័ន, ការបែងចែកភារកិច្ច និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់, ការធ្វើសវនកម្ម និងអធិការកិច្ចលើអង្គភាពប្រមូលចំណូល, និងការដាក់ទោសទណ្ឌ ដោយអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តនានា ជាពិសេសអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ;
- ពង្រឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ឱ្យបានពេញលេញនៅថ្នាក់ជាតិ និងឈានទៅពង្រីកប្រព័ន្ធនេះនៅថ្នាក់ក្រោមជាតិ;
- រៀបចំប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយអនុវត្តសាកល្បងជាប្រព័ន្ធក្រៅបណ្តាញ (offline system) សម្រាប់ក្រសួង-ស្ថាប័ន, មន្ទីររាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់;

- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងច្បាប់ស្តីពីការគ្រប់គ្រង, ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ;
- ពិនិត្យឡើងវិញនូវលក្ខខណ្ឌនៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ ឱ្យស្របតាមការការវិវឌ្ឍនៃសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន;
- បន្តពិនិត្យ និងកែសម្រួលកម្រងសេវាសាធារណៈ ដើម្បីពិនិត្យលទ្ធភាពដាក់បញ្ចូលនូវប្រភពចំណូលថ្មីបន្ថែមទៀត ស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកម្ពុជា;
- រៀបចំប្រកាសអន្តរក្រសួង លើការចែករំលែកចំណូលសេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អនុលោមតាមគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាល;
- ពន្លឿននីតិវិធីរៀបចំឡើងវិញនូវកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធឱ្យកាន់តែមានប្រសិទ្ធភាព ខណៈបន្តការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច ឱ្យអស់សក្តានុពលដោយផ្អែកលើគោលការណ៍ និងបទប្បញ្ញត្តិជាធរមាន;
- បន្តសិក្សា និងរៀបចំជាបណ្តើរៗនូវក្របខ័ណ្ឌគតិយុត្តថ្មីស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈឱ្យស្របតាមការវិវឌ្ឍនៃសកម្មភាពសេដ្ឋកិច្ចកម្ពុជាជាក់ស្តែង ក្នុងន័យជំរុញការអភិវឌ្ឍសហគ្រាសសាធារណៈ, ការបង់ចំណូលភាគលាភចូលថវិកាជាតិឱ្យបានត្រឹមត្រូវ និងការផ្តល់របាយការណ៍ដែលបានធ្វើសវនកម្មឯករាជ្យ;
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលមិនមែនសារពើពន្ធ តាមរយៈការពង្រឹងយន្តការអន្តរ-ក្រសួងដែលមានស្រាប់ និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីទប់ស្កាត់ការកើតមានបំណុលថ្មី, ការតឹងទារបំណុល និងការលុបបំណុលរ៉ាំរ៉ៃដែលមិនអាចទារបាន;
- ពន្លឿនការអនុវត្តយន្តការកំណត់ និងបង់កម្រៃសេវា រួមមាន កម្រៃលេខទូរគមនាគមន៍, កម្រៃពីប្រេកង់ និងជំរុញការកែប្រែឡើងវិញនូវកម្រៃអាជ្ញាបណ្ណឱ្យបានសមស្រប និងគ្រប់ជ្រុងជ្រោយ;
- រៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីវិស័យប្រៃសណីយ៍;
- ប្រើប្រាស់ទិន្នន័យពីមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យទូរគមនាគមន៍ (DMC) ជាមូលដ្ឋានក្នុងការកំណត់ការបែងចែកប្រាក់ចំណូល និងសម្រាប់ផ្ទៀងផ្ទាត់ជាមួយចំណូលសារពើពន្ធ;
- បង្កើនសមត្ថភាពចរចាជាមួយភាគីពាក់ព័ន្ធ និងរៀបចំយន្តការគ្រប់គ្រងប្រភពចំណូល ដែលមានសក្តានុពលក្នុងវិស័យរ៉ែ និងថាមពល ដូចជាចំណូលពីសម្បទាន និងចំណូលពីការបែងចែកផល (equity share) ឱ្យមានប្រសិទ្ធភាព;
- បន្តជំរុញការស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសិក្សាកែតម្រូវប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណទេសចរណ៍ ដើម្បីសម្រួលដល់អាជីវកម្ម និងគ្រប់គ្រងអាជីវកម្មទេសចរណ៍ថ្មីៗ;

- បន្តអភិវឌ្ឍប្រព័ន្ធកំណត់ចំណាត់ថ្នាក់សេវាកម្មទេសចរណ៍គ្រប់ប្រភេទ និងជំរុញឱ្យគ្រប់ម្ចាស់អាជីវកម្ម សេវាកម្មទេសចរណ៍ស្នើសុំការវាយតម្លៃចំណាត់ថ្នាក់តាមប្រព័ន្ធ;
- ពង្រឹងការអនុវត្តប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីការគ្រប់គ្រងចំណូលពីកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋានឱ្យមានប្រសិទ្ធភាព និងជំរុញការអនុវត្តកាតព្វកិច្ចបង់ចំណូលតាមកិច្ចសន្យាជួលឱ្យបានពេញលេញ;
- ជំរុញការអនុម័តច្បាប់ស្តីពីរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្ម និងរៀបចំលិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិគាំទ្រដល់ច្បាប់;
- ពង្រឹងប្រសិទ្ធភាពនៃការកៀរគរចំណូលឱ្យអស់លទ្ធភាពពីអាជីវកម្មល្បែងភ្នាល់គ្រប់ប្រភេទ
- តាមរយៈការពន្លឿនការអនុវត្តបទដ្ឋានគតិយុត្តជាធរមានដែលពាក់ព័ន្ធនឹងកាស៊ីណូ, ល្បែងភ្នាល់, រមណីយដ្ឋាន សមាហរណ និងល្បែងពាណិជ្ជកម្មផ្សេងទៀត;
- ធ្វើប្រតិភូកម្មការចេញលិខិតអនុញ្ញាតអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទានខ្នាតតូច និងកម្រៃដែលទទួលបានពីលិខិតនេះ ជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី-ខេត្ត;
- ពង្រឹងយន្តការត្រួតពិនិត្យ និងការអនុវត្តក្របខ័ណ្ឌបទប្បញ្ញត្តិដែលមានជាធរមាន ដើម្បីធ្វើការដាក់ពិន័យចំពោះគ្រឹះស្ថានជានារ៉ាប់រង និងសោធន ដែលមិនអនុលោមតាមច្បាប់ និងបទ-ប្បញ្ញត្តិ;
- ដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្ម និងសេវាកម្មអចលនវត្ថុ ក្នុងគោលដៅជំរុញឱ្យក្រុមហ៊ុនប្រកបអាជីវកម្មគ្មានអាជ្ញាបណ្ណ មកស្នើសុំអាជ្ញាបណ្ណពីក្រសួងស្របតាមច្បាប់ជាធរមាន
- ដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងអាជីវកម្មពុះដីឡូតិ៍លក់។

## ខ. វិធានការផ្នែកចំណាយ

ក្នុងក្របខ័ណ្ឌនៃគោលដៅទ្រទ្រង់ចលនការនៃការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងបរិការណ៍នៃការកើនឡើងនូវភាពមិនច្បាស់លាស់ និងហានិភ័យពាក់ព័ន្ធ ជាពិសេសលទ្ធភាពនៃការដក EBA ដោយសហភាពអឺរ៉ុប រាជរដ្ឋាភិបាល ចាំបាច់ត្រូវអនុវត្តវិធានការជាក់លាក់ និងមុតស្រួច ដើម្បីបង្កើនប្រសិទ្ធភាពចំណាយក្នុងឆ្នាំ ២០២០ ដូចខាងក្រោម÷

- គិតគូរឱ្យមានកញ្ចប់ថវិកាត្រៀមបម្រុងសម្រាប់ដោះស្រាយតម្រូវការបន្ទាន់ និងចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាល ក្នុងករណីមានវិបត្តិផ្សេងៗ និងប្រធានស័ក្តិ;
- បន្តបង្កើនការឆ្លើយតបនៃថវិកាទៅនឹងគោលនយោបាយអាទិភាពតាមវិស័យរបស់រាជរដ្ឋាភិបាល តាមរយៈ ការបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកាឈរលើមូលដ្ឋានចាំបាច់ជាក់ស្តែង និងចំទិសដៅ ជាពិសេស ការពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងប្រសិទ្ធភាពក្នុងការអនុវត្តថវិកា;

- កំណត់លក្ខខណ្ឌជ្រើសរើសក្របខ័ណ្ឌថ្មី សម្រាប់ទាំងផ្នែកមន្ត្រីរាជការស៊ីវិល យោធិន នគរបាលជាតិ និងស្ថាប័នឯករាជ្យ ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ លើកលែងតែក្រសួងអាទិភាព ដែលទទួលបានគោលការណ៍ឯកភាពដោយក្រសួងមុខងារសាធារណៈ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាមី;
- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធក្នុងគោលដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, សមធម៌, សង្គតិភាព, គុណាធិបតេយ្យ និងចីរភាពថវិកា;
- បន្តគាំទ្រការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ តាមរយៈការបន្តអនុវត្តគោលការណ៍បង្កើនប្រាក់សោធននិវត្តន៍សម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ព្រមទាំងកាត់បន្ថយគម្លាតរវាងអ្នកចូលនិវត្តន៍ចាស់ និងថ្មី;
- បន្តរក្សាអាទិភាព និងវិចារណកម្មចំណាយនៅក្នុងវិស័យអប់រំ, បណ្តុះបណ្តាលវិជ្ជាជីវៈ, ប្រព័ន្ធដឹកជញ្ជូននិងឡូជីស្ទីក, កសិកម្ម, សហគ្រិនភាព និងសេដ្ឋកិច្ចឌីជីថល ជាដើម;
- ពង្រឹងការអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកានៅគ្រប់ក្រសួង-ស្ថាប័នទាំងនៅរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី-ខេត្ត និងពង្រីកការសាកល្បងនៅថ្នាក់ក្រោមជាតិ;
- ដាក់ឱ្យអនុវត្តអនុក្រឹត្យគោលស្តីពីក្របខ័ណ្ឌរួម សម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈក្នុងស្រុករួមមាន÷ ១). ការរៀបចំផែនការមេវិនិយោគសាធារណៈរយៈពេលមធ្យមរបស់ក្រសួង-ស្ថាប័ន, ២). ការកំណត់គោលការណ៍ និងលក្ខខណ្ឌវិនិច្ឆ័យគម្រោងដែលតម្រូវឱ្យមានការសិក្សាសមិទ្ធលទ្ធភាព និង ៣). ការធ្វើសមាហរណកម្មប្រតិទិននៃការរៀបចំផែនការគម្រោងវិនិយោគទៅនឹងប្រតិទិនរៀបចំថវិកា;
- បង្កើនទំហំ និងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈលើការពង្រីក និងពង្រឹងគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់, ផ្លូវដែក, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី និងប្រព័ន្ធទូរគមនាគមន៍ ក្នុងគោលបំណងបង្កើនភាពប្រកួតប្រជែងកម្ពុជា និងបង្កើតការងារជូនប្រជាពលរដ្ឋ ក្នុងនោះជំរុញឱ្យបញ្ចប់ផែនការយុទ្ធសាស្ត្ររយៈពេលវែង និងផែនការមេតាមវិស័យសំខាន់ៗនេះ;
- ពង្រឹងការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវរាល់វិធានការ, បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈជាធរមាន ដើម្បីបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាពនៃចំណាយសាធារណៈ;
- បន្តជំរុញការធ្វើវិសហមជ្ឈការការត្រួតពិនិត្យហិរញ្ញវត្ថុ តាមរយៈការផ្ទេរសិទ្ធិអំណាចក្នុងការចាត់ចែងចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅក្រសួង-ស្ថាប័ន និងពីអង្គភាពហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន ទៅអង្គភាពអនុវត្តការងារផ្ទាល់;

- បន្តកាត់បន្ថយនីតិវិធីចំណាយ ជាពិសេសបរិបទចំណាយថ្មីសម្រាប់ការអនុវត្តថវិកាកម្មវិធី តាមរយៈការប្តូរពីការត្រួតពិនិត្យមុនចំណាយ ទៅត្រួតពិនិត្យក្រោយចំណាយ និងដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) នៅតាមក្រសួង-ស្ថាប័ន;
- ជំរុញការរៀបចំគោលនយោបាយ និងក្របខ័ណ្ឌវិមជ្ឈការហិរញ្ញវត្ថុរយៈពេលខ្លី និងវែង ដើម្បីបន្តរួមចំណែកក្នុងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរាជធានី-ខេត្ត និងក្រុង-ស្រុក ជាពិសេសកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ;
- បន្តអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងបំណុលសាធារណៈរបស់រាជរដ្ឋាភិបាលក្នុងគោលដៅរក្សាចីរភាពបំណុលទៅតាមវិធានការគោលនយោបាយគន្លឹះដែលបានគ្រោង រួមមាន÷
  - កំណត់ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ ១,៥ ប៊ីលាន ទៅ ២ ប៊ីលាន អេសដេអ៊ែរ ក្នុងមួយឆ្នាំ ទៅតាមបរិការណ៍នៃគោលនយោបាយថវិកា និងវិវឌ្ឍនាការម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែងរបស់កម្ពុជា;
  - រក្សាអនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស (រួមទាំងបំណុលដែលមានការធានាពីរដ្ឋ) ធៀបនឹង ផសស (present value of external public debt to GDP) ឱ្យស្ថិតក្រោម ៤០%;
  - បន្តពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ, ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ និងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន តាមរយៈ÷ ១). ការអនុវត្តប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធី និងបែបបទអនុវត្ត ចំណាយវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ ឱ្យកាន់តែមានភាពច្បាស់លាស់ គ្រប់ដំណាក់កាល, ២). ការធ្វើបច្ចុប្បន្នកម្មនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ និង ៣). ការរៀបចំបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន;
  - បន្តធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានទូលំទូលាយជាងមុន តាមរយៈការបន្តកៀរគរហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ, វិស័យឯកជនក្រោមក្របខ័ណ្ឌនៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន, និងទីផ្សារមូលបត្រ និង
  - បន្តពង្រឹងការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងហានិភ័យបំណុល ជាពិសេសតាមដាននិងត្រួតពិនិត្យហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុដែលអាចកើតចេញពី÷ ១). ការធានារបស់រដ្ឋលើគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន, ២). វិស័យធនាគារ និងហិរញ្ញវត្ថុ និង ៣). ក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈប្រហាក់ប្រហែល, គ្រឹះស្ថានសាធារណៈ, សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- បន្តអនុវត្តវិធានការគន្លឹះ ក្នុងទិសដៅពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន÷

- ពង្រឹងគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលរាជធានី-ខេត្ត) ឱ្យបានទាន់ពេលវេលា ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការថវិកាប្រចាំឆ្នាំ;
- ដាក់រដ្ឋបាលរាជធានី-ខេត្ត ទាំង ២៥ អនុវត្តថវិកាកម្មវិធី ដើម្បីធានាបាននូវភាពផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកាឱ្យចំគោលដៅអាទិភាព និងប្រសិទ្ធភាពនៃការអនុវត្តថវិកា;
- ជំរុញការរៀបចំសៀវភៅថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធី ឱ្យបានទាន់ពេលវេលា ដើម្បីបញ្ចូលក្នុងប្រព័ន្ធ FMIS និង
- រៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទប្បញ្ញត្តិ សម្រាប់ប្រតិបត្តិការចំណូល-ចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចជា÷ អនុក្រឹត្យស្តីពីការបន្ថែមធនធានចំណាយអភិវឌ្ឍន៍មូលដ្ឋានជូនរដ្ឋបាល ឃុំ-សង្កាត់, អនុក្រឹត្យស្តីពីការគ្រប់គ្រង និងការបែងចែកចំណូលកម្រៃសេវារដ្ឋបាល នៃអង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត, និងប្រកាសអន្តរក្រសួងស្តីពីការកែសម្រួលចំណូលពីសេវាសាធារណៈជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ។

## ២.៣-ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២០-២០២២

ក្របខ័ណ្ឌថវិការយៈពេលមធ្យម(**ក.ថ.ម**) ត្រូវបានរៀបចំឡើងដើម្បីអនុវត្តសាកល្បងចាប់ពីឆ្នាំ ២០២០ និងផ្តោតជាសំខាន់លើការកំណត់**ពិតានចំណាយគោលនៃចំណាយចរន្តសិន** ដើម្បីធានាភាពជាក់លាក់នូវហិរញ្ញប្បទានផ្នែកចំណាយចរន្ត។ ការកំណត់ពិតានចំណាយគោលដល់កម្រិតក្រសួង-ស្ថាប័ន ធ្វើឡើងដើម្បីពង្រឹងគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (**ផ.យ.ថ**), បន្តពង្រឹងវិន័យថវិកា, បង្កើនប្រសិទ្ធភាពចំណាយ និងកែលម្អការវិភាជធនធានសាធារណៈជារួម ។

នៅក្នុងការចាប់ផ្តើមអនុវត្តសាកល្បងនេះ, ***ការកំណត់ពិតានចំណាយគោល*** *(Baseline Ceiling)* ***ត្រូវបានជ្រើសរើសជាអភិក្រមនៃការអនុវត្ត ដើម្បីផ្តល់មូលដ្ឋានច្បាស់លាស់មួយក្នុងផ្តល់កញ្ចប់ថវិកា*** ព្រោះជាទូទៅការស្នើសុំកញ្ចប់ថវិការបស់ក្រសួង-ស្ថាប័ននាពេលបច្ចុប្បន្ន នៅមិនទាន់មានមូលដ្ឋានគិតគូរ និងគណនាបានត្រឹម-ត្រូវទៅតាមកម្មវិធីនីមួយៗ ក៏ដូចជាក្នុងការដាក់ចេញសូចនាករសមិទ្ធកម្មនៅឡើយ។ **ពិតានចំណាយគោល** ***"គឺជាកញ្ចប់ថវិកាដែលក្រសួង-ស្ថាប័នអាចនឹងទទួលបានសម្រាប់ប្រតិបត្តិការសកម្មភាពការងារ និងកម្មវិធីដែលមានលក្ខណៈជាប្រចាំ ដោយគិតគូរបញ្ចូលនូវកត្តាតម្រូវការ*** *(demand driver)* ***ប៉ុន្តែត្រូវបានកាត់ចេញនូវទំហំចំណាយនៃគោលនយោបាយ និង/ឬ សកម្មភាពមិនប្រចាំ និង/ឬ លទ្ធភាពដែលត្រូវបានវាយតម្លៃថាមិនមានប្រសិទ្ធភាព, ដោយឡែកចំពោះចំណាយសម្រាប់ការកែលម្អផលិតភាពការងារ, ការលើកកម្ពស់ប្រសិទ្ធភាព និងការអនុវត្តគោលនយោបាយថ្មី នឹងផ្តល់ជូនបន្ថែមទៀតតាមលទ្ធភាពថវិកាជាក់ស្តែងក្នុងឆ្នាំនីមួយៗ ហើយកញ្ចប់ថវិកាទាំងនេះនឹងត្រូវសម្រេចតាមរយៈការពិភាក្សាចរចាថវិកាប្រចាំឆ្នាំ"***។ អភិក្រមនេះនឹងត្រូវកែលម្អជាបណ្តើរៗរហូតដល់

ឆ្នាំ ២០២៥ ដើម្បីប្រែក្លាយ **ក.ថ.ម** ឱ្យក្លាយជាក្របខ័ណ្ឌដែលធានាបានធនធានហិរញ្ញវត្ថុ និងថវិកាកាន់តែច្បាស់លាស់សម្រាប់រយៈពេលមធ្យម សម្រាប់គាំទ្រដល់ការសម្រេចបានគោលបំណងគោលនយោបាយ ។

តាមគោលការណ៍នេះ រូបមន្តពិតានចំណាយគោលរបស់ក្រសួង-ស្ថាប័ន និងឧបត្ថម្ភធនគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានគិតគូរគណនាដោយផ្អែកជាចម្បងលើថវិកាចំណាយប្រចាំនៃឆ្នាំថវិកា (ឆ្នាំ N) ដោយបូកបន្ថែមថវិកាសម្រាប់អនុវត្តគោលនយោបាយថ្មីដែលអនុម័តនៅឆ្នាំថវិកា (ឆ្នាំ N) និងត្រូវចាត់ទុកជាចំណាយប្រចាំសម្រាប់ឆ្នាំគ្រោងថវិកា (ឆ្នាំ N+1) ប៉ុន្តែត្រូវកាត់ចេញវិញនូវចំណាយមិនប្រចាំ ។ បន្ទាប់ពីនេះ ថវិកាចំណាយប្រចាំនៃឆ្នាំថវិកា (ឆ្នាំ N) ត្រូវកាត់ចេញនូវថវិកាសម្រាប់អនុវត្តគោលនយោបាយដែលអនុម័ត នៅឆ្នាំមុន (ឆ្នាំ N-1) ដែលមិនបានអនុវត្ត ។ ដោយឡែក សមាសធាតុផ្សេងៗទៀត ដូចជា អត្រាប្រែប្រួលនៃប្រាក់បៀវត្ស កត្តាអតិផរណា និងកត្តាតម្រូវការ នឹងត្រូវសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្អែកលើការប្រជុំពិភាក្សាជាមួយនឹងក្រសួង-ស្ថាប័ននីមួយៗ។ សរុបមក **ពិដានចំណាយគោលឆ្នាំ** ២០២០-២០២២ ផ្តល់នូវការធានាធនធានហិរញ្ញវត្ថុ និងថវិកា**ជូនដល់គ្រប់ក្រសួង-ស្ថាប័ន** ***ដូចដែលបានរៀបចំ និងមានភ្ជាប់ជូនក្នុងតារាង ១ និងឧបសម្ព័ន្ធ ១*** សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២។

## ៣-រចនាសម្ព័ន្ធ និងគោលការណ៍នៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ បានកំណត់គោលដៅរួមនៃការប្រមូលចំណូល ដោយបានដាក់ចេញនូវវិធានការចាំបាច់ និងជាក់ស្តែងដែលត្រូវអនុវត្តក្នុងឆ្នាំ ដើម្បីសម្រេចគោលដៅទាំងនេះ និងបានកំណត់គោលដៅរួមនៃការអនុវត្តចំណាយ និងដាក់ចេញអាទិភាពគោលនយោបាយសំខាន់ៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូច្នេះ ក្រសួង-ស្ថាប័ននីមួយៗត្រូវផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចបានកំណត់ខាងលើ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ឱ្យបានល្អត្រឹមត្រូវតាមទិសដៅនេះ និងជាក់ស្តែង។ ទន្ទឹមនេះ ដើម្បីជាមូលដ្ឋានសម្រាប់ក្រសួង-ស្ថាប័ន អាចរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈឯកភាពគ្នាទាំងរចនាសម្ព័ន្ធ និងទាំងខ្លឹមសារ ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ននីមួយៗត្រូវបានរៀបចំតាមទម្រង់ដូចខាងក្រោម÷

- **ផ្នែកទី១: អំពីសេចក្តីផ្តើម**

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២ របស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវបានរៀបចំឡើងដោយចាប់ផ្តើមគូសរំលេចអំពីតួនាទី និងបេសកកម្មរបស់ក្រសួង-ស្ថាប័ន, អំពីស្ថានភាពជាក់ស្តែងនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ និងការប៉ាន់ស្មានស្ថានភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៩-២០២១ ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ និងលើកឡើងបញ្ហាប្រឈមដែលត្រូវដោះស្រាយក្នុងឆ្នាំ ២០១៩ និងឆ្នាំខាងមុខ។ បន្ទាប់មកត្រូវបរិយាយរំលេចផងដែរ អំពីវិធានការគោលនយោបាយសំខាន់ៗ

ដែលក្រសួង-ស្ថាប័នបានដាក់ចេញ រួមទាំងគោលនយោបាយតាមវិស័យ និងអន្តរវិស័យ។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី ១ នេះ ទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- **ផ្នែកទី២: អំពីគោលបំណងគោលនយោបាយ**

គោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ត្រូវបានរៀបចំ*ដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និង* និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣។ ទោះបីជារួម គោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ មិនមែនជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ប៉ុន្តែក្រសួង-ស្ថាប័នខ្លះ គួរពិនិត្យឡើងវិញនូវគោលបំណងគោលនយោបាយ ដោយផ្សារភ្ជាប់ទៅនឹងអាទិភាពគោល-នយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី ៦ នៃរដ្ឋសភាជាតិ ដើម្បីធានាថាគោលនយោបាយដែលបានកំណត់មានភាពត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ និងឆ្លើយតបបានកាន់តែច្បាស់លាស់ ទៅនឹងគោលនយោបាយតាមវិស័យរបស់ខ្លួន និងគោលដៅរួមរបស់រាជរដ្ឋាភិបាល។ **ជាគោលការណ៍ *ក្រសួង-ស្ថាប័ននីមួយៗត្រូវមានគោលបំណងគោល-នយោបាយមិនលើសពី ០២ ឡើយ*** ។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី ២ នេះទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- **ផ្នែកទី៣: អំពីកម្មវិធី**

*ការរៀបចំកម្មវិធី ត្រូវឆ្លើយតបនឹងគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងត្រូវពណ៌នាអំពីគោលបំណងនៃកម្មវិធីនីមួយៗឱ្យបានច្បាស់លាស់ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ពីការផ្សារភ្ជាប់រវាងកម្មវិធីទៅនឹងគោលនយោបាយ*។ ដូច្នេះ នៅក្នុងផ្នែកនេះ *គ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពថវិកាត្រូវពិនិត្យឡើងវិញនូវឈ្មោះកម្មវិធី និងកែសម្រួលឱ្យកាន់តែល្អប្រសើរនូវឈ្មោះកម្មវិធីទាំងនោះ ដើម្បីពង្រឹងគុណភាពរចនាសម្ព័ន្ធកម្មវិធីក្នុងគោលបំណងពង្រឹងបន្ថែមទៀតនូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយក្នុងដំណើរឈានទៅអនុវត្តថវិកាសមិទ្ធកម្មដែលនឹងចាប់អនុវត្តពីឆ្នាំ ២០២២*។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគិតគូរដល់ការចូលរួមអនុវត្តការងារដែលមានចរិតជាអន្តរវិស័យ ដូចជា គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម បញ្ហាយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ពីគ្រោះមហន្តរាយជាដើមផងដែរ។ ចំពោះការគាំទ្រផ្នែកបច្ចេកទេសលើរបៀបរៀបចំគម្រោងថវិកាដែលទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ក្រសួង-ស្ថាប័នពាក់ព័ន្ធអាចធ្វើទំនាក់ទំនងផ្ទាល់ជាមួយនឹងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនៃក្រសួងបរិស្ថានពាក់ព័ន្ធនឹងកិច្ចការនេះ។ ជាគោលការណ៍ ***ក្រសួង-ស្ថាប័ន នីមួយៗអាចមានកម្មវិធីមិនឱ្យលើសពីចំនួន ៥ ឡើយ*** ប៉ុន្តែចំពោះអនុកម្មវិធីអាចមានចំនួនសមស្របទៅតាមការចាំបាច់ ដែលបម្រើឱ្យគោលបំណងរួមនៃកម្មវិធីនីមួយៗ។

កម្មវិធី គឺជាឧបករណ៍ដែលបង្កើតឡើង ដើម្បីឱ្យអគ្គនាយកដ្ឋាន/នាយកដ្ឋាន ក្រោមឱវាទរបស់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលស្ថិតក្រោមក្រសួង-ស្ថាប័នសាមី ដាក់ចេញនូវអនុកម្មវិធី និងចង្កោមសកម្មភាព ព្រមទាំងជាមូលដ្ឋានសម្រាប់ការលើកគម្រោងថវិកាដើម្បីអនុវត្តកម្មវិធីទាំងនោះ ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផ្នែកទី ២។ គួរកត់សម្គាល់

ថា ចង្កោមសកម្មភាពសំដៅលើសកម្មភាពចម្បងៗ ដែលអាចមានចំនួនសមស្របទៅតាមការចាំបាច់សម្រាប់បម្រើឱ្យគោលបំណងរួមនៃអនុកម្មវិធីនីមួយៗ ហើយចង្កោមសកម្មភាពមួយ អាចមានសកម្មភាពតូចៗមួយចំនួនដែលរួមចំណែកបង្កើតផលិតផលចេញ (Output) សម្រាប់ចង្កោមសកម្មភាពនោះ ។

កម្មវិធី ត្រូវមានខ្លឹមសារទូលាយ និងមានលក្ខណៈគ្របដណ្តប់បានទាំងស្រុង គ្រប់តួនាទីភារកិច្ច និងបេសកកម្មរបស់ក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំងមានលក្ខណៈសមាហរណកម្ម ដោយត្រូវគ្របដណ្តប់លើគម្រោង ឬ សកម្មភាពការងារទាំងអស់ ទាំងគម្រោង ឬសកម្មភាពការងារដែលហិរញ្ញប្បទានដោយថវិការដ្ឋ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ទាំងថវិកាចរន្ត និងថវិកាមូលធន។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័ន ត្រូវកំណត់អង្គភាពទទួលខុសត្រូវ ដែលហៅថា **អង្គភាពថវិកា** និងអ្នកគ្រប់គ្រងទៅតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធី (កម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព)។

ទន្ទឹមនេះ ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ប្រព័ន្ធថវិកា ក្រសួង-ស្ថាប័ននីមួយៗ ត្រូវកំណត់ភារកិច្ច វិសាលភាពការងារ និងក្របខ័ណ្ឌទទួលខុសត្រូវរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តឱ្យច្បាស់លាស់នៅក្នុងរចនាសម្ព័ន្ធកម្មវិធី។ មន្ទីរជំនាញរាជធានី-ខេត្ត មិនចាំបាច់ត្រូវមានកម្មវិធីដោយឡែកទេ ព្រោះមន្ទីរជំនាញរាជធានី-ខេត្ត គឺជាដៃ ឬខ្សែបណ្តោយរបស់ក្រសួង នៅតាមរាជធានី-ខេត្ត ដែលមានភារកិច្ចចូលរួមចំណែកអនុវត្តបណ្តាកម្មវិធីរបស់ក្រសួង-ស្ថាប័ន។

ក្នុងន័យនេះ **ក្រសួង-ស្ថាប័ននីមួយៗ ត្រូវណែនាំមន្ទីរជំនាញនៅរាជធានី-ខេត្តរៀងខ្លួន អំពីអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីនីមួយៗ ដោយផ្អែកលើមុខងារ វិសាលភាពការងារ និងលក្ខណៈដោយឡែកនៃគោលនយោបាយ និងសេវាសាធារណៈរបស់ក្រសួង-ស្ថាប័នរៀងខ្លួន ដើម្បីឱ្យមន្ទីរជំនាញរាជធានី-ខេត្ត របស់ខ្លួនដឹងច្បាស់អំពីទីតាំងនៃអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីនីមួយៗរបស់ក្រសួង-ស្ថាប័នរៀងខ្លួន។ ជាទូទៅ មន្ទីរជំនាញមួយអាចមានចង្កោមសកម្មភាពគាំទ្រគ្រប់កម្មវិធីរបស់ក្រសួង-ស្ថាប័ន ឬអាចមានចង្កោមសកម្មភាពគាំទ្រ ២ ទៅ ៣ ដោយផ្អែកតាមមុខងារ និងភារកិច្ចរបស់មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ននីមួយៗ។** ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **ត្រូវរៀបចំផ្នែកទី ៣ នេះ ទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- **ផ្នែកទី៤: សូចនាករ និងគោលដៅសូចនាករ នៃសមិទ្ធកម្ម ឬ លទ្ធផល**

គោលបំណងគោលនយោបាយ កម្មវិធី និងអនុកម្មវិធីនីមួយៗ ត្រូវមានសូចនាករសម្រាប់វាស់វែងលទ្ធផល ឬ សមិទ្ធកម្ម ហើយត្រូវកំណត់គោលដៅសូចនាករលទ្ធផលដែលចង់សម្រេចបានសម្រាប់ជាមូលដ្ឋាននៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្ត។ ក្នុងការកំណត់សូចនាករសម្រាប់ការវាស់វែង ក្រសួង-ស្ថាប័ននីមួយៗ ត្រូវកំណត់ទាំងសូចនាករលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ។

សូចនាករលទ្ធផលក្នុងឆ្នាំ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/សមិទ្ធកម្មនៃការអនុវត្តកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព ទៅតាមគោលដៅដែលបានកំណត់ក្នុងរយៈពេលជាក់លាក់មួយដែលមិន

លើសពីមួយឆ្នាំ។ រីឯសូចនាករលទ្ធផលចុងក្រោយ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/សមិទ្ធកម្មចុងក្រោយនៃកម្មវិធី។

ក្រសួង-ស្ថាប័ននីមួយៗ អាចកែលម្អសូចនាករតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធីនីមួយៗ តាមរយៈការបន្ថែមសូចនាករថ្មី និងកែសម្រួលសូចនាករចាស់ដែលបានកំណត់កន្លងមក។ ការជ្រើសរើសសូចនាករនីមួយៗ ត្រូវមានការពន្យល់ពីមូលហេតុឱ្យច្បាស់លាស់។ ចំពោះសូចនាករចាស់ត្រូវបញ្ជាក់អំពីស្ថានភាពនៃការអនុវត្តឆ្នាំ ២០១៨ ការព្យាករស្ថានភាពនៃការអនុវត្តក្នុងឆ្នាំ ២០១៩ និងធ្វើបច្ចុប្បន្នភាពតាមការជាក់ស្តែង។

**កម្មវិធីនីមួយៗ អាចមានសូចនាករលទ្ធផលចុងក្រោយយ៉ាងច្រើនចំនួន ៣ និងសូចនាករលទ្ធផលក្នុងឆ្នាំមួយចំនួន** ដើម្បីធានានូវការសម្រេចបានលទ្ធផលជាក់លាក់នៃការអនុវត្តកម្មវិធី។ ជារួម បន្ទាប់ពីការជ្រើសរើស និងកំណត់បាននូវសូចនាករសមស្របរួចហើយ ចាំបាច់ត្រូវកំណត់គោលដៅនៃសូចនាករ ទាំងគោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ និងគោលដៅសូចនាករលទ្ធផលចុងក្រោយ។ គោលដៅសូចនាករទាំងពីរប្រភេទនេះចាំបាច់ត្រូវឱ្យមានទំនាក់ទំនងគ្នា និងឆ្លើយតបគ្នាយ៉ាងមានប្រសិទ្ធភាព ដើម្បីធានានូវការសម្រេចបានលទ្ធផលនៃគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយ។ គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំមានលក្ខណៈជាបរិមាណ ឬ/និងជាគុណភាពប្រចាំឆ្នាំ ដែលជាសមិទ្ធកម្មនៃការអនុវត្ត កម្មវិធីនីមួយៗ។ រីឯគោលដៅសូចនាករលទ្ធផលចុងក្រោយ គឺជាគោលដៅសមិទ្ធកម្មចុងក្រោយជាបរិមាណឬ/និងជាគុណភាព ដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី នៅក្នុងរយៈពេល មធ្យមនិងវែង (លើសពី១ឆ្នាំ)។ ក្នុងការកំណត់គោលដៅសូចនាករ កត្តាចាំបាច់និងសំខាន់បំផុត គឺត្រូវដឹងអំពីស្ថានភាពបច្ចុប្បន្នរបស់សូចនាករទាំងនោះទើបអាចទៅកំណត់គោលដៅដែលចង់បាន ដើម្បីឱ្យឆ្លើយតបបាន ទៅនឹងគោលបំណងគោលនយោបាយដែលបានកំណត់ ហើយការកំណត់គោលដៅនេះ ចាំបាច់ត្រូវតែមាន ភាពសមស្របនិងប្រាកដនិយមដែលអាចអនុវត្តបាន។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៤ នេះទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។ ចាប់ពីឆ្នាំ ២០២០ ទៅ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្តោតការយកចិត្តទុកដាក់ជាបណ្តើរៗលើសមិទ្ធកម្ម ដែលតម្រូវឱ្យក្រសួង-ស្ថាប័នយកចិត្តទុកដាក់កែលម្អសូចនាករឱ្យបានល្អប្រសើរ និងមានមូលដ្ឋានទិន្នន័យច្បាស់លាស់។**

- **ផ្នែកទី៥: ការកំណត់ធនធានថវិកា**

ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគ្រោងទាំងធនធានថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តកម្មវិធី សម្រាប់រយៈពេលបីឆ្នាំរំកិល ២០២០-២០២២។

### ក-ការគ្រោងចំណូល

ការគ្រោងចំណូល គឺជាការគ្រោងសម្រាប់រយៈពេល ៣ ឆ្នាំ ២០២០-២០២២ ដោយរួមទាំងចំណូលថវិការដ្ឋដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង-ស្ថាប័ន និងចំណូលដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងប្រភពផ្សេងៗទៀត។ នៅក្នុងការគ្រោងចំណូល ក្រសួង-ស្ថាប័ន រួមទាំង

មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម÷

- គោលដៅសូចនាករចំណូលនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញនៅក្នុងសារាចរនេះ
- ការវាយតម្លៃការអនុវត្តការប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត
- ការដាក់ចេញវិធានការជាក់ស្តែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ ដើម្បីបង្កើនការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំផ្នែកនេះទៅតាម **តារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។ នៅក្នុងផ្នែកនេះ ប្រសិនបើក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ ។

ទន្ទឹមនេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានប្រភពចំណូល គឺត្រូវរៀបចំដាក់ចេញវិធានការជាក់ស្តែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ *ផ្ទុយទៅវិញ ការគ្រោងចំណូលមិនអស់សក្តានុពលដែលមាន គឺជាកម្មវត្ថុនៃការរឹតត្បិតចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់ក្រសួង-ស្ថាប័ន ដែលមានភារកិច្ចប្រមូលចំណូល*។

**ខ-ការគ្រោងចំណាយថវិកា**

ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល ៣ ឆ្នាំ ២០២០-២០២២ ទៅតាមកម្មវិធីនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន រួមទាំងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៥ នេះ **តាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។

ក្នុងការគណនាអំពីតម្រូវការថវិកា ដើម្បីអនុវត្តកម្មវិធីនីមួយៗ ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម÷

ទី១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលរាជរដ្ឋាភិបាលបានដាក់ចេញ តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមានគោលដៅសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចជា កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងគោលដៅសូចនាករចំណាយ ព្រមជាមួយនឹងគោលនយោបាយអាទិភាពចំណាយទាំងផ្នែកចំណាយចរន្ត និង ចំណាយមូលធន (ឬហៅថា ចំណាយវិនិយោគ)។ ***ដូចគ្នានេះដែរ ពិតានចំណាយគោលនៃចំណាយចរន្តរបស់ក្រសួង-ស្ថាប័ន ត្រូវបានផ្តល់ជាកញ្ចប់ថវិកាសម្រាប់រយៈពេល ៣ ឆ្នាំ (២០២០-២០២២) ទាំងផ្នែកចំណាយបន្ទុកបុគ្គលិក ដែលមានកំណើនស្របតាមគោលនយោបាយ***

*បៀវត្សរបស់រាជរដ្ឋាភិបាល (ដោយមិនគិតបញ្ចូលនូវប្រាក់ពីសេវាសាធារណៈ) និងចំណាយមិនមែនបន្ទុកបុគ្គលិកទៅតាមគោលការណ៍ដែលលម្អិតនៅក្នុងផ្នែក* ***២.៣***។

ទី២- ការវាយតម្លៃអំពីសមត្ថភាពក្នុងការអនុវត្តចំណាយក្នុងរយៈពេលកន្លងមក និងការប៉ាន់ស្មានសមត្ថភាពអនុវត្តចំណាយក្នុងឆ្នាំ ២០១៩ ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗបាននិងកំពុងអនុវត្ត,

ទី៣- ការកំណត់តម្រូវការថវិកាតាមឆ្នាំនីមួយៗ ត្រូវគណនាចំណាយប្រកបដោយសុក្រឹតភាពទៅតាមតម្រូវការជាក់ស្តែងនៃកម្មវិធីនីមួយៗ ដោយត្រូវគិតគូរឈរលើទិដ្ឋភាពបី ÷

- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានស្រាប់ដែលត្រូវបន្តអនុវត្ត ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងខ្លួន,
- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានលក្ខណៈបញ្ចប់ត្រឹមមួយឆ្នាំ , និង
- ផែនការសកម្មភាព ឬសកម្មភាពការងារថ្មី ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងខ្លួន។

ដូច្នេះ ផ្អែកលើគោលការណ៍ទាំងបីខាងលើនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទទាំងអស់ ត្រូវគ្រោងតម្រូវការចំណាយសម្រាប់ឆ្នាំ ២០២០-២០២២ តាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា ដូចខាងក្រោម÷

- **ចំណាយបន្ទុកបុគ្គលិក** (ជំពូក ៦៤)÷ សម្រាប់ឆ្នាំ ២០២០ ត្រូវគ្រោងតាមមូលដ្ឋាននៃក្របខ័ណ្ឌ និងកម្រិតបៀវត្សឆ្នាំ ២០១៩ គឺតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០១៩។ ដោយឡែកសម្រាប់ឆ្នាំ ២០២១ និង ២០២២ ត្រូវគ្រោងដោយផ្អែកលើមូលដ្ឋាននៃកម្រិតក្របខ័ណ្ឌ និងកម្រិតបៀវត្សលើមូលដ្ឋានឆ្នាំ ២០២០ និងឆ្នាំ ២០២១ រៀងគ្នា ហើយចំនួនក្របខ័ណ្ឌថ្មីត្រូវគ្រោងជ្រើសរើសយ៉ាងច្រើនស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ នឹងចេញគោលការណ៍លម្អិតសម្រាប់ការដំឡើងបៀវត្សមូលដ្ឋាន និងការដំឡើងប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធសម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំ ២០២០ នាពេលខាងមុខ។
- **ចំណាយក្រៅបន្ទុកបុគ្គលិក** (ជំពូក៦០ ការទិញ, ជំពូក៦១ សេវាកម្ម, ជំពូក៦២ អត្ថប្រយោជន៍សង្គម, ជំពូក៦៥ ឧបត្ថម្ភធន) ជាសរុបសម្រាប់ឆ្នាំ ២០២០ ត្រូវគ្រោងតាមគោលការណ៍ ដូចខាងក្រោម÷
  - **ក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល**÷ ត្រូវគ្រោងថវិកាទៅតាមទំហំពិតានចំណាយគោលឆ្នាំ ២០២០-២០២២ ប៉ុន្តែត្រូវកត់សម្គាល់ថា កញ្ចប់ថវិកានៃពិតានចំណាយគោលនេះ មិនទទួលបានជាស្វ័យប្រវត្តិនោះទេ។ រាល់ការគ្រោងចំណាយទាំងអស់ ត្រូវភ្ជាប់ជាមួយនូវ

ឯកសារពាក់ព័ន្ធ រួមមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាចរចា នៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។ មានន័យថា ពិតានចំណាយគោលនៅតែជាកម្មវត្ថុនៃការកាត់តម្រឹមនៅពេលចរចាថវិកាប្រចាំឆ្នាំ ដើម្បីបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា។

- **មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ន÷** ផ្អែកលើទំហំពិតានចំណាយគោលរួមដែលផ្តល់ជូនដល់មន្ទីរជំនាញរាជធានី-ខេត្ត, សម្រាប់ឆ្នាំ ២០២០ មន្ទីរជំនាញរាជធានី-ខេត្តនីមួយៗ ត្រូវគ្រោងយ៉ាងច្រើនបំផុតស្មើនឹងកម្រិតថវិកាអតិបរមានៃច្បាប់ឆ្នាំ ២០១៩ និងសម្រាប់ឆ្នាំ ២០២១ និង ឆ្នាំ ២០២២ ត្រូវគ្រោងកើនឡើងក្នុងរង្វង់នៃ**ទំហំពិតានចំណាយគោលរួមដែលមានកំណើនរួមក្នុងរង្វង់ ៣% ធៀបនឹងទំហំពិតានចំណាយគោលរួមឆ្នាំ ២០២០។ ប៉ុន្តែ ត្រូវកត់សម្គាល់ថា កញ្ចប់ថវិកាដែលគ្រោងផ្តល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី-ខេត្ត**នីមួយៗ ត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។
- **គ្រឹះស្ថានសាធារណៈរដ្ឋបាលនៃក្រសួង-ស្ថាប័ននីមួយៗ** ត្រូវបានផ្តល់កញ្ចប់ថវិកាឧបត្ថម្ភធនសម្រាប់រយៈពេល ០៣ ឆ្នាំ (២០២០-២០២២) **ប៉ុន្តែ ត្រូវកត់សម្គាល់ថា កញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្តល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ** គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវផ្តល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទៃក្នុងរបស់គ្រឹះស្ថាន និង ម្យ៉ាងទៀត ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់។

- **ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានថវិកាជាតិ** (ជំពូក២១) សម្រាប់ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, និង ក្រសួងធនធានទឹកនិងឧតុនិយម ត្រូវបន្តអនុវត្តតាមយន្តការគណៈកម្មការអន្តរក្រសួង ដោយធ្វើអាទិភាវូបនីយកម្មគម្រោង សម្រាប់អនុវត្តឆ្នាំ ២០២០ ២០២១ និង ២០២២ ក្នុងទំហំថវិកាប្រហាក់ប្រហែលនឹងឆ្នាំ ២០១៩ ។ ដោយឡែក ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលមានតម្រូវការចំណាយវិនិយោគ ត្រូវសិក្សានិងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំអាទិភាវូបនីយកម្មគោរពសុំការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចទៅតាមលទ្ធភាពថវិកាក្នុងដំណាក់កាលរៀបចំថវិកាប្រចាំឆ្នាំ។

- **ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍ** ក្រសួង-ស្ថាប័ន ដែលបាន និងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទាន ស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០២០-២០២២) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅ តាមកិច្ចព្រមព្រៀង ឬ អនុស្សារណៈនៃការយោគយល់គ្នា ឬ ការសន្យាតាមរយៈយន្តការផ្សេងៗ។

- **ផ្នែកទី៦: សេចក្តីសន្និដ្ឋាន**

ផ្នែកចុងក្រោយ គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២ និង ការលើកទិសដៅ និងវិធានការ ដើម្បីសម្រេចគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២។

## ៤. សេចក្តីសន្និដ្ឋាន

ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាព នៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាវិធានការសំខាន់សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំថវិកា និង ការបែងចែកធនធានថវិកា។ ក្នុងន័យនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈ រដ្ឋបាលនីមួយៗ ត្រូវត្រួតពិនិត្យឡើងវិញ និងវាយតម្លៃការអនុវត្តកន្លងមក ហើយរៀបចំកែសម្រួលទៅតាម ការណែនាំនៃសារាចរនេះ។ ជារួម *គុណភាពនៃផែនការយុទ្ធសាស្ត្រ គឺជាកម្មវត្ថុនៃការរឹតត្បិត ឬ លើកទឹកចិត្ត ចំណាយនៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់គ្រប់ក្រសួង-ស្ថាប័ន។*

សម្រាប់ឆ្នាំ ២០២០ និងបណ្តាឆ្នាំខាងមុខ, ក្រសួង ស្ថាប័នត្រូវយកចិត្តទុកដាក់កែលម្អផែនការយុទ្ធសាស្ត្រ ថវិកាឱ្យស្របទៅតាមអាទិភាពគោលនយោបាយ ដែលមាននៅក្នុង***យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤*** ដែលជារបៀបវារៈគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមរបស់រាជរដ្ឋាភិបាលអាណត្តិទី ៦ នៃរដ្ឋសភាជាតិ និង ត្រូវគ្រោងចំណាយស្របទៅតាមពិដានគោលរយៈពេលបីឆ្នាំ និងធនធានដទៃទៀតដែលរំពឹងថានឹងទទួល បានពីដៃគូអភិវឌ្ឍ ឬប្រភពដ៏ទៃផ្សេងទៀត ប្រកបដោយភាពជាក់ស្តែងនិយម ។

*គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០២០-២០២២ ដែលមាន វិសាលភាពគ្របដណ្តប់ទាំងផែនការយុទ្ធសាស្ត្រថវិការបស់មន្ទីរជំនាញរាជធានី-ខេត្ត និងរបស់គ្រឹះស្ថានសាធារណៈ រដ្ឋបាល មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៩* ដើម្បីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យនិងបូកសរុប និងស្នើសុំការបំភ្លឺបន្ថែមតាមការចាំបាច់ពីក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ដើម្បីសម្រួលដល់ដំណើរការពិនិត្យ និងបូកសរុបផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ននីមួយៗ *មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថាន សាធារណៈរដ្ឋបាល ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាមួយច្បាប់ទៅក្រសួង-ស្ថាប័នសាមី និងមួយច្បាប់មក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) តាមពេលវេលា ដែលបានកំណត់ ខាងលើ។* ប្រសិនបើក្រសួង-ស្ថាប័នមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកា តាមពេលវេលាកំណត់ខាងលើ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យស្នើការវិភាជកញ្ចប់ថវិកាប្រចាំឆ្នាំ ដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកាឆ្នាំចាស់ និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ។

ទទួលបានសារាចរណែនាំនេះ ក្រសួង-ស្ថាប័ន រួមទាំងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងឱ្យបានទាន់ឱសានវាទ។ ក្នុងករណីក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេសរៀបចំ ត្រូវទាក់ទងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២ **ឱ្យបានទាន់ពេលវេលាតាមកាលកំណត់ និងផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៩។**

ថ្ងៃពុធ ៦ កើតខែចេត្រឆ្នាំចសំរឹទ្ធិស័កព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមេសាឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

"ដើម្បីជូនជ្រាប"

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-រាជកិច្ច "ដើម្បីចុះផ្សាយ"

-គ្រប់ក្រសួង-ស្ថាប័ន

-គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល

-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត

-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត

"ដើម្បីមុខការ"

-ឯកសារ-កាលប្បវត្តិ